# ការសិក្សាស្រាវជ្រាវអំពី

# កម្ពុជា និង យៀកកុង

# CAMBODIA & THE VIET CONG

**December 1965**

**INDOCHINA ARCHIVE**
**University California**

ការផ្សាយរបស់សារពត៌មានអង្គរបុរី
រក្សាសិទ្ធិគ្រប់យ៉ាង
(ខែមេសា ឆ្នាំ២០០៨)

# សេចក្តីសង្ខេប

បញ្ហាទំនាក់ទំនងកម្ពុជាជាមួយយៀកកុង ប្រមូលផ្តុំលើលក្ខណៈទ្រង់ទ្រាយពីរ មួយគឺនយោបាយការបរទេសរបស់សីហនុ និងការជះឥទ្ធិពលមកលើ ចេញពីការ រីកដុះដាលកាន់តែធំឡើងៗ នៃចលនាកុម្មុយនិស្តនិយមនៅយួនខាងត្បូង ។ មួយចំណែកទៀត គឺការប្រើប្រាស់ទឹកដីខ្មែររបស់ពួកយៀកកុង ដើម្បីធ្វើជាប្រភពទីកន្លែង ផ្តល់ស្បៀង, ទីជំរក និងជាការសំរួលកិច្ចការផ្នែកនយោបាយ ។

ការស៊ើបអង្កេតដ៏ហ្មត់ចត់មួយ ពីគ្រប់ជ្រុងជ្រោយបញ្ជាក់ថា ពួកយៀកកុងទទួលស្បៀងនៅខាងក្នុងនិងឆ្លងតាមរយៈប្រទេសកម្ពុជា ក៏ប៉ុន្តែបានបង្ហាញថា ទំហំនៃ ការផ្តល់ស្បៀងនោះតិចតួចទេ បើប្រៀបធៀបទៅនឹងការទទួលផ្ទាល់តាមរយៈប្រទេសលាវ និងពីខាងក្នុងរង្វង់ប្រទេសយួនខាងត្បូង ។ វាជាការច្បាស់ណាស់ ដែលថា មានការឃុបឃិតស៊ីគ្រលុំនៃពួកមន្ត្រីខ្មែរ បណ្តាលឲ្យពួកយៀកកុងទាំងអស់នេះរស់នៅយ៉ាងសុខសប្បាយ ក្នុងតំបន់ជាច្រើនតាមបណ្តោយព្រំដែនខ្មែរ ។ ពួកកុម្មុយនិស្តក៏បានរៀបចំផងដែរ នូវទីកន្លែងងាយស្រួលតូចៗជាសម្ងាត់នៅលើទឹកដីខ្មែរ ។ ការបញ្ជាក់ទាំងអស់បានបង្ហាញឲ្យដឹងថា ទីកន្លែងសំរួលការទាំងនេះ គឺជាផ្នែកមួយ ដ៏តូចប៉ុណ្ណោះ នៃការខិតខំប្រឹងប្រែងទាំងអម្បាលមាណរបស់ពួកកុម្មុយនិស្ត នៅ ឯស្រុកយួនខាងត្បូង ។

នេះហើយជាភស្តុតាងយ៉ាងសំខាន់ដែលឆ្លុះបង្ហាញឲ្យឃើញ ទោះបីរដ្ឋាភិបាលខ្មែរមានឬក៏ពុំមានចេតនាសមគំនិតជាមួយប្រតិបត្តិការរបស់ពួកយៀកកុងនៅក្នុងស្រុកខ្លួនក៏ដោយ ។ សីហនុកំពុងមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗចំពោះ ការថ្កោលទោសដែលថា ស្រុកខ្មែរបានត្រូវប្រើប្រាស់ដោយពួកយៀកកុង ។ ដល់ដូច្នេះទៅ រដ្ឋាភិបាលភ្នំពេញបានសាកល្បងរិះរកមធ្យោបាយទប់ទល់ចំពោះការប្រើប្រាស់បែបនេះ ដោយប្រើនូវលទ្ធភាពរបស់ខ្លួនដើម្បីត្រួតពិនិត្យទៅលើព្រំដែនមាន ប្រវែង៦០០ម៉ៃល៍របស់ខ្លួនជាមួយប្រទេសយួន ដែលខ្លួនពុំអាចនឹងធ្វើអ្វីបានទាល់តែសោះនោះ ។

# បរិបទនយោបាយ

១- ការសំរុះសំរួលមួយដែលបានធ្វើឡើងនៅទីក្រុងហ្សឺណែវកាលពីឆ្នាំ១៩៥៤ អាចរាប់ថាជាព្រឹត្តិការណ៍មួយដ៏ល្អ សំរាប់សេចក្តីសង្ឃឹមនៃរដ្ឋាភិបាលភ្នំពេញ ។ ឯករាជភាពថ្មីៗនៃប្រទេសកម្ពុជា ក៏បានត្រូវសហគមអន្តរជាតិធ្វើឲ្យត្រឹមត្រូវស្របច្បាប់។ បូរណភាពទឹកដី ដែលជាចំណាប់អារម្មណ៍មួយដ៏ធំក្រៃលែងនៅភ្នំពេញត្រូវបានធានាដោយប្រទេសហត្ថលេខី ។ ទោះការធានានេះមើលឃើញពីក្រៅជាងការពិតក៏ដោយ ក៏វាគ្រាន់បើជាងគ្មានបានធ្វើអ្វីទាំងអស់ ។ ការសំរុះសំរួលក៏បានបញ្ឈប់ផងដែរ នូវការវាយប្រយុទ្ធគ្នា ចំពេលដែលសង្គ្រាមកំពុងរាលដាលហូរកំពប់ចូលទៅក្នុងទឹកដីខ្មែរ។ ជាមួយការចចេសមានះនិងភាពរឹងរូស មិនសមហេតុផលនិងជាប្រជាជាតិអប្រសិទ្ធិភាពយ៉ាងណាក្តី, ពួកគណៈប្រតិភូខ្មែរបានធ្វើការតវ៉ាទាមទាររួចហើយក៏បានទទួលនូវជ័យជំនះ លើការដកកងទ័ពយៀកមិញថយចេញពីទឹកដីខ្មែរ ។ រដ្ឋាភិបាលសីហនុសំរេចចិត្ត មិនចាប់ផ្តើមធ្វើការកាន់កាប់គ្រប់គ្រងរបស់ខ្លួនទៅលើទឹកន្លែងទាំងអស់នោះ ដោយធ្វើការវាយប្រហារប្រឆាំងពីរដងទៅលើទេ ។

២- ប្រហែលដែលល្អប្រសើរជាងអ្វីទាំងនោះ, កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវបានបន្សល់ឲ្យស្រុកយួនបែកជាពីរនិងទន់ខ្សោយ ។ ដំណើរប្រវត្តិសាស្ត្រយួនធ្វើឲ្យស្រុតចុះនៃឧបទ្វីប ត្រូវបានគេប្រមើមើល ។ កិច្ចការនយោបាយក្រៅប្រទេសរបស់ខ្មែរ ក៏ត្រូវរក្សាទុកនូវសភាពការណ៍ដដែល ។

៣- ចំពោះសីហនុហើយនិងពលរដ្ឋខ្មែរឯទៀត, កត្តាដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រសម័យថ្មីនៃឧបទ្វីបឥណ្ឌូចិន គឺមិនទុកបណ្តែតបណ្តោយឲ្យមានគំនាបសង្កត់មកលើទឹកដីខ្មែរ ពីសំណាក់ប្រទេសថៃនិងយួនឡើយ ។ កត្តាផ្សេងទៀត, អាណានិគមនិយមបារាំង ព្រមទាំងការប្រយុទ្ធតស៊ូរវាងសហរដ្ឋអាមេរិកជាមួយនឹងកុម្មុយនិស្តចិន ក៏មានសារៈសំខាន់ណាស់ដែរ ។ នៅក្នុងការធ្វើវិភាគចុងក្រោយ, ទោះបីយ៉ាងណាក៏ដោយ, អ្វីទាំងអស់នេះ គឺគ្របទៅលើបញ្ហាជាមូលដ្ឋានចក្រពត្តិនិយមឬអាណានិគមនិយមរបស់ថៃនិងយួន ។

៤- នៅក្នុងការប្រយុទ្ធតស៊ូដើម្បីបូរណភាពទឹកដីរបស់ខ្លួន, ខ្មែរបានត្រូវខិនខ្វង់ដោយសារភាពទន់ជ្រាយរបស់ខ្លួន ដោយពុំអាចប្រៀបផ្ទឹមទៅនឹងកម្លាំងរបស់ថៃនិងយួនបានឡើយ ។ ដល់ដូច្នេះទៅ ខ្មែរត្រូវបង្ខំចិត្តរំពឹងទៅលើវិធីការទូត ។ កាលពីសតវត្សទី១៩, ពេលខ្ពង់ទៅទល់នឹងជញ្ជាំង, ខ្មែរបានរត់ទៅពឹងបារាំងឲ្យមកជួយការពារខ្លួនពីពួកប្រទេសជិតខាងដ៏ខ្លាំងក្លា។ អំពើអាណាព្យាបាលបារាំង, បើតាមការ

យល់ឃើញរបស់ខ្មែរ, ពុំមែនជាពាក្យសំរាប់បន្ទរនោះទេ។ បើបារាំងពិតជាមានតម្លៃខ្ពង់ខ្ពស់សំរាប់ការការពារមែន, បើបារាំងទន្ទ្រានជិះជាន់ធ្ងន់ធ្ងរទៅលើអធិបតេយ្យភាពខ្មែរមែន, នោះវាជារឿងអកុសលមួយ ។ រឿងដែលសំខាន់នោះគឺថា ស្រុកខ្មែរត្រូវបានថែរក្សាឲ្យស្ថិតនៅគង់វង់ដដែល ។

៥- ស្ថានការណ៍បានប្រែប្រួលក្នុងអំឡុងឆ្នាំ១៩៥០ ។ គំនិតជាតិនិយមដែលផុសផុលឡើងនៅក្រោយពេលសង្គ្រាមទូទាំងឥណ្ឌូចិន ក៏បានឱ្យតនៅក្នុងដួងចិត្តនៃពួកយុវជនរៀនសូត្រចេះដឹងខ្មែរជាច្រើន រួមទាំងសីហនុផង ។ ស្រុកខ្មែរមិនអាចបន្តធ្វើជាអាណានិគមបារាំងរហូតនោះទេ ។ សំខាន់ជាងនេះ, ទោះបីមានការពិតដែលនិយាយថា អំណាចពិតប្រាកដនៅឥណ្ឌូចិនកំពុងត្រូវផ្លាស់ប្តូរក៏ដោយ ។ ចំពោះខ្មែរបារាំងគឺជាកម្លាំងដែលទន់ខ្សោយ ហើយមហាអំណាចមួយថ្មីទៀតត្រូវតែចូលខ្លួនមកជំនួស ប្រសិនណាបើខ្មែរចង់ថែរក្សាការពារបូរណភាពទឹកដីរបស់ខ្លួន ។

៦- សីហនុពុំមែនជាជនទ្រឹស្តីនិយមទេ ហើយនៅពេលគាត់ប្រកាន់យក«គំនិតអព្យាក្រឹត្យនិយម» ធ្វើជាមាគ៌ានយោបាយក្រៅប្រទេសរបស់ខ្មែរ គឺមកពីគិតថាមានតែរូបមន្ត«អាព្យាក្រឹត្យនិយម»នេះហើយ ជាបែបបទដ៏សមស្រួនដែលប្រជាជាតិទើបបានឯករាជ្យថ្មោងថ្មីត្រូវប្រកាន់យក, ហើយសីហនុក៏គ្មានមន្ទិលសង្ស័យអ្វីសោះឡើយ ក្នុងការប្រយ័ត្នប្រយែងឃុំគ្រងស្រុកខ្មែរឲ្យស្ថិតនៅជាយ៉ាងដូច្នេះ ។ ដែលសំខាន់ជាងនេះនោះ, «នយោបាយអព្យាក្រឹត្យនិយម», បានផ្តោតទៅលើវិធានការខាងផ្លូវទូត ជាជាងការប្រើដំណោះស្រាយយោធាទៅលើបញ្ហានានា ហើយព្រមទាំងផ្តោតទៅលើការចៀសវាងប្រចូកច្របល់ស្មុគស្មាញនៅក្នុងសង្គ្រាមត្រជាក់ ដោយអនុលោមទៅតាមគោលចំហរជាប្រពៃណីរបស់ខ្មែរ និងភាពពិតជាក់ស្តែងនៅក្នុងឥណ្ឌូចិន ។ សីហនុបានសំរេចយក«នយោបាយអព្យាក្រឹត្យនិយម» តែមួយគត់ទោះបីយ៉ាងដូចម្តេចក៏ដោយ ។ ចំពោះទស្សនៈរបស់គាត់, អព្យាក្រឹតភាពអាចធ្វើឲ្យប្រជាជាតិតូចតាច ប្រើប្រាស់ការប្រទាញប្រទង់មិនស្មើភាពគ្នានៃឥទ្ធិពល ដែលកំពុងប្រណាំងប្រជែងគ្នារវាងមហាអំណាចមួយជាមួយនឹងមហាអំណាចមួយទៀត ។

៧- សីហនុលេងល្បែងនេះយ៉ាងប៉ិនប្រសប់អស់ចំនួនដប់ឆ្នាំ ។ គាត់បានចាត់ចែងថែរក្សាជួសជុលទំនាក់ទំនងរបស់គាត់ជាមួយសហរដ្ឋអាមេរិកយ៉ាងល្អ ទោះបីគាត់មានអារម្មណ៍ថា សហរដ្ឋអាមេរិកមានការពាក់ព័ន្ធអំពើទុច្ចរិតជាមួយសៀមនិងយួនខាងត្បូង ប្រឆាំងរដ្ឋាភិបាលរបស់គាត់ក៏ដោយ ។ នៅពេលជាមួយគ្នានោះ, ទោះបីយ៉ាងណាក៏ដោយ, គាត់បានធ្វើទំនាក់ទំនងជាមួយចិនកុម្មុយនិស្ត កាន់តែប្រសើរឡើងបន្តិចម្តងៗជាលំដាប់ ។ ការថ្លឹងថ្លែងនេះចាប់ផ្តើមផុះឡើងនៅដើមទសវត្សរ៍ឆ្នាំហុកសិប ដោយសារកម្លាំងកុម្មុយនិស្តកាន់តែខ្លាំងឡើងៗនៅឯយួនខាងត្បូង ។

៨- ល្អិកណាពួកយៀកកុងគ្មានបង្កការប្រកួតប្រជែងអ្វីស័ក្តិសិទ្ធិ ចំពោះរដ្ឋាភិ-បាលក្រុងសៃហ្គងទេ, អំពើកុបកម្មគឺគ្រាន់តែជាការរឿងបន្ទាប់បន្សំប៉ុណ្ណោះចំពោះខ្មែរ ។ រហូតដល់ដើមឆ្នាំ១៩៥៨, ដំណើរកើនឡើងជាបន្តបន្ទាប់នៃសកម្មភាពទ័ពព្រៃ ក៏ចាប់ផ្ដើមប៉ះទង្គិចដល់ទំនាក់ទំនងរវាងសៃហ្គងនិងភ្នំពេញ ។ នៅចុងខែមិថុ-នា, មួយយប់មុនពេលការចេញដំណើររបស់សីហនុ ទៅជួបនិយាយគ្នាជាមួយសៃ-ហ្គង, ពួកកងទ័ពយួនបានធ្វើការដេញតាមបាញ់ប្រហារពួកយៀកកុង រួចហើយបានកាន់កាប់ភូមិខ្មែរមួយក្នុងរយៈពេលយ៉ាងខ្លីផង ។ ឧប្បត្តិហេតុនេះ គឺជាអំពើរំលោភឈ្លានទីមួយនៅក្នុងរយៈវេលាដ៏យូរកន្លងមក ដែលធ្វើឲ្យមានការថ្កោលទោសគ្នាទៅវិញទៅមក រួចហើយសីហនុក៏លុបចោលការធ្វើដំណើររបស់គាត់នោះទៅ ។

៩- ទោះបីសកម្មភាពពួកយៀកកុង មានតួនាទីសំខាន់កាន់តែច្រើនឡើងៗ ទៅលើទំនាក់ទំនងដ៏អាប់អួររវាងសៃហ្គងនិងភ្នំពេញក៏ដោយ, គេគ្មានឃើញសញ្ញាណាមួយចង្អុលប្រាប់ថា នៅទសវត្សទីហាសិបនិងដើមទសវត្សទីហុកសិប សីហនុជឿថា ការប៉ាន់ប្រមាណជាថ្មីនៃនយោបាយរបស់គាត់ចំពោះរដ្ឋាភិបាលយៀម ចាំបាច់ដែរឬទេ ។ ជាការផ្ទុយទៅវិញ, គាត់បានសារភាពថា វត្តមានរបបប្រឆាំងកុម្មុយនិស្តនៅយួនខាងត្បូង គឺជួយដល់ខ្មែរទៅវិញទេ ។ ក្នុងបទសម្ភាសន៍មួយជាមួយកាសែតបារាំង Le Monde, សីហនុបាននិយាយយ៉ាងចំហថា ៖ «ដើម្បីរក្សាទំនាក់ទំនងល្អជាមួយមិត្តកុម្មុយនិស្តរបស់ខ្ញុំ, នោះយើងមិនត្រូវមានព្រំដែនជាប់ជាមួយគ្នាទេ» ។

១០- មានចំណុចខ្លះ, ដូចកាលពីដើមឆ្នាំ១៩៦១, សីហនុស្រាប់ជឿថា ពួកយៀកកុងពិតជាឈ្នះសង្គ្រាមនៅយួនខាងត្បូង ។ គាត់សម្លឹងមើលឃើញដោយភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់យល់ថា ជាការជាប់ផុងលង់ទ្រនេសរបស់អាមេរិកាំងក្នុងស្ថានភាពនៅយួនខាងត្បូង ឆ្ពោះទៅរកបរាជ័យ ។ គាត់បានស្នើឲ្យធ្វើការចរចាជាមួយពួកទ័ពព្រៃ ក្នុងពេលកម្លាំងពួកនេះនៅមិនទាន់ខ្លាំងមែនទែននៅឡើយ ។ វត្ថុបំណងនៃការចរចា គឺដើម្បីធ្វើឲ្យយួនខាងត្បូង«ទៅជាអព្យាក្រឹត្យ» ដែលគាត់ចង់មានន័យថា ទុកឲ្យយួននៅបែកគ្នា ។ ការទទួចរបស់គាត់សុំឲ្យមាន«សន្និសិទទីក្រុងហ្សឺណែវ»ចាប់ពីឆ្នាំ១៩៦២មក គឺនៅក្នុងទម្រង់នយោបាយនេះឯងហើយ ។

១១- ការងាកនៃខ្មែរទៅខាងឆ្វេង បានដំណើរការយ៉ាងហោចណាស់ក៏ចាប់តាំងពីឆ្នាំ១៩៦១ដែរ រួចហើយបានប្រកាសឲ្យដឹងនៅឆ្នាំ១៩៦៣ ។ ទំនាក់ទំនងរវាងភ្នំពេញនិងសហរដ្ឋអាមេរិក បានថមថយចុះដោយហេតុមកពីសហរដ្ឋអាមេរិកមិនគាំទ្រការចរចាជាមួយពួកកុម្មុយនិស្ត ។ នៅក្នុងពេលជាមួយគ្នានោះ, សីហនុបានលាតត្រដាងបង្ហាញឲ្យឃើញនូវគំរោងការ អំពីអ្វីដែលគាត់ជឿថា គឺការសំរបសំរួលជាចាំបាច់ជាមួយហាណូយនិងប៉េកាំង ។ បញ្ហាសំរាប់សីហនុ គឺធ្វើយ៉ាងណាឲ្យទំនង់ទំនង

នោះកាន់តែល្អប្រសើរឡើងៗ ។

១២- នាចុងឆ្នាំ១៩៦៤, សីហនុជាលើកទីមួយ ចាប់ផ្ដើមនិយាយយ៉ាងចេញមុខទទួលស្គាល់ផ្លូវទូត ពុំមែនគ្រាន់តែជាមួយយួនខាងជើងប៉ុណ្ណោះទេ គឺជាមួយនឹងពួកយៀកកុងផងដែរ។ ស្ថានភាពយ៉ាប់យ៉ឺននៅស្រុកយួនខាងត្បូង តែងតែជាការគិតគូរទុកមុនរបស់សីហនុជានិច្ច រួចហើយគ្មានអ្វីត្រូវមន្ទិលសង្ស័យទៀតឡើយ ដែលធ្វើឲ្យគាត់ដើរចូលកាន់តែជ្រៅៗទៅខាងឆ្វេង ។ សីហនុស្ទើតែប្រាកដជំរុញឲ្យទៅជាយ៉ាងដូច្នេះ ដោយសារការអស់សង្ឃឹមបន្តនូវបរាជ័យចំពោះអ្វីដែលគាត់ចង់បានជាទីបំផុត ក្នុងរយៈពេល២ឆ្នាំកន្លងមក គឺការធ្វើសន្និសិទហ្សឺណែវស្ដីពីឥណ្ឌូចិន ដែលគាត់ចង់បញ្ចេញឲ្យគេឃើញនូវជំនាញការខាងទូតរបស់គាត់ដើម្បីដោះស្រាយបញ្ហា ដែលកំពុងគ្របដណ្ដប់កាន់តែខ្លាំងឡើងៗ ដោយកម្លាំងអាវុធយុទ្ធភ័ណ្ឌនិងមនុស្ស ។ ចំពោះសីហនុ, សន្និសិទហ្សឺណែវថ្មីធ្វើឡើង នៅក្នុងសេចក្ដីរំពឹងទៅលើ «ដំណោះស្រាយអព្យាក្រឹត្យ»សំរាប់ស្រុកយួនខាងត្បូង ។ គាត់នៅមានសង្ឃឹមថា ទោះបីគាត់ជឿជាក់ថា ថ្វីបើការបន្តជោគជ័យរបស់ពួកយៀកកុងបានកើនឡើងមែនពិតយ៉ាងណាក៏ដោយ ការធ្វើឲ្យយួនខាងត្បូង, កម្ពុជា និងស្រុកសៀម ក្លាយទៅជាអព្យាក្រឹត្យ អាចជារបងមួយខណ្ឌចែកមហាអំណាចខាងកើតនិងខាងលិច មិនឲ្យប៉ះទង្គិចគ្នាបាន ក្នុងពេលទុកឲ្យស្រុកយួននៅតែបែកគ្នា ។

១៣- សីហនុសុខចិត្តគាំទ្រប៉េកាំង រហូតដល់ចេញមុខនិយាយជំនួសចិនក្នុងបញ្ហាអន្តរជាតិនានា នៅក្នុងក្របខ័ណ្ឌប្រយោជន៍ខ្មែរ ។ ក្នុងពេលនិយាយគ្នាមួយនៅប៉េកាំងកាលពីចុងឆ្នាំទៅ (ឆ្នាំ១៩៦៤), យួនខាងជើងនិងយៀកកុងបានដឹងជាលើកទីមួយ នូវអ្វីដែលពួកគេសង្ស័យជាយូរមកហើយ គឺសីហនុជាអ្នកចរចាម្នាក់ដ៏ស្វិតស្វាញអស្ចារ្យ អំពីបញ្ហាណាដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ខ្មែរ ។ ពេលពួកកុម្មុយនិស្តប្រកែកមិនព្រមចុះញ៉ម ចំពោះការទាមទារហួសហេតុរបស់សីហនុ ការចរចាគ្នាក៏ត្រូវចប់ ។ ចំពោះសីហនុ, រឿងបែបនេះគឺគ្មានអ្វីក្រៅអំពីការមិនស្មោះត្រង់របស់យួនប៉ុណ្ណោះ ដែលជានយោបាយកំហែងមកលើកម្ពុជា ។ ក្នុងសុន្ទរកថាដ៏គួរឲ្យកត់សម្គាល់មួយនៅភ្នំពេញកាលពីដើមឆ្នាំនេះ គឺនៅក្នុងពេលគាត់ធ្វើជាពិធីការពួកខាងឆ្វេងក្នុងសន្និសិទប្រជាជនឥណ្ឌូចិន, សីហនុបានព្រមានដល់កងទ័ពខ្មែរថា ៖ «ពួកចក្រពត្តិនិយមយួន ទោះបីមានពណ៌បែបណាក៏ដោយ គឺជាគ្រោះថ្នាក់យ៉ាងពិតប្រាកដចំពោះខ្មែរ» ។

១៤- នៅក្នុងសន្និសិទ ការកំហែងរបស់យួនទាំងពីរ ក្រោមអនុត្តរភាពកុម្មុយនិស្តនេះ, សីហនុបានងាកទៅរកស្រុកចិនកុម្មុយនិស្ត នៅក្នុងសេចក្ដីសង្ឃឹម ហើយគាត់បានសារភាពថា ទោះតិចតួចយ៉ាងណាក៏ដោយ ចិននឹងប្រើប្រាស់ឥទ្ធិពលរបស់

ខ្លួនដើម្បីទប់យួនដែរ ។ ដូចកាលពីដើមឆ្នាំ១៩៦០, ចិនបានត្រូវគេរាយការណ៍ឲ្យដឹងថាបានសន្យា«ប្រើឥទ្ធិពលរបស់ខ្លួន»ជាមួយហូ-ជីមិញ ដើម្បីបញ្ចុះបញ្ចូលពួកយៀកកុង ឲ្យគោរពអព្យាក្រឹត្យភាពខ្មែរ ហើយនិងចៀសវាងបង្កឧប្បត្តិហេតុនៅជិតព្រំដែនខ្មែរ ។ វាជាការច្បាស់ណាស់ដែលថា សីហនុមានជំនឿតិចតួចបំផុតចំពោះការសន្យានិងការធានារបស់យួនបែបនេះ ។ គាត់កាន់តែគ្មានជំនឿជាងនេះទៅទៀត ចំ-ពោះលទ្ធភាពរបស់សហរដ្ឋអាមេរិក ដែលអាចត្រាំត្រែងនៅក្នុងអាស៊ីអាគ្នេយ៍ ។

១៥- ល្គិកណាសីហនុជឿថា ពួកយៀកកុងនឹងឈ្នះសង្គ្រាមនៅយួនខាងត្បូង ហើយសហរដ្ឋអាមេរិកត្រូវតែបង្ខំធ្វើការចរចាដើម្បីរកច្រកចេញនោះ, យើងក៏អាចសម្លឹងមើលឃើញថា ស្រុកខ្មែរមុខជាប្រកាន់ជំហររបស់ខ្លួនងាកទៅខាងឆ្វេង ។

ដោយការបន្តហៅស្រុកខ្មែរ ជាស្រុក«អព្យាក្រឹត្យ», ទោះបីយ៉ាងណាក៏ដោយ, សីហនុចង្អុលបង្ហាញថា គាត់ពុំទាន់បានប្រុងប្រៀបកាត់ផ្តាច់ចំណងទាក់ទងគ្នាទាំងអស់នៅឡើយទេ ។ គាត់បានរកឃើញរួចហើយថា ការកាត់ផ្តាច់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក និងការកាត់បន្ថយចុះទំនាក់ទំនងរបស់គាត់ជាមួយខាងលិច មុខជានឹងធ្វើឲ្យគាត់មានទីកន្លែងតូចចង្អៀតខ្លាំងណាស់ សំរាប់ចាត់ការខាងផ្លូវទូត ។ គេសង្កេតឃើញមានសញ្ញាបញ្ជាក់យ៉ាងច្បាស់ថា សីហនុសង្ឃឹមធ្វើការជួសជុលនូវការខូចខាតខ្លះ ដោយធ្វើឲ្យល្អប្រសើរឡើងទំនាក់ទំនងជាមួយចក្រភពអង់គ្លេសនិងប្រទេសអូស្ត្រាលី ។ មូលដ្ឋាននៃការប្រែប្រួលនៅក្នុងស្រុកខ្មែរ គឺវាអាស្រ័យទៅលើដំណើរការនៃសង្គ្រាមនៅស្រុកយួនខាងត្បូងឯណោះទេ ។

## យៀកកុងប្រើប្រាស់ស្រុកខ្មែរ

១៦- ទោះបីគេឃើញច្បាស់ថា ពួកយៀកកុងបានប្រើប្រាស់ទឹកដីខ្មែរ ចាប់តាំងពីថ្ងៃដំបូងអើយនៃការបះបោររបស់ពួកគេនៅក្នុងស្រុកយួនខាងត្បូងក៏ដោយ, ទំហំនៃការប្រើប្រាស់និងទំនាក់ទំនងដ៏សំខាន់ក្នុងសង្គ្រាមទ័ពព្រៃ ពុំដែលច្បាស់ទាល់តែសោះ ។ បញ្ហានោះគឺថា មកពីការខំលាក់បំពួនខ្លួនតាមធម្មជាតិនៃពួកកុម្មុយនិស្ត ព្រមទាំងទីកន្លែងដែលពុំមាននរណាអាចចូលទៅដល់ ។ បន្ថែមពីលើនោះទៀត និងរាប់សិបឆ្នាំមកហើយ ក្រដាស់ប្រាក់ដែលពួកគេប្រើ បើតាមសេចក្តីរាយការណ៍ គឺគ្មាននរណាដឹងប្រភពបានមកពីណាទេ ហើយតម្លៃនៃក្រដាស់ប្រាក់នោះទៀតសោ-ត ក៏គួរឲ្យមន្ទិលសង្ស័យក្រៃលែង ។

## ស្បៀង

១៧- ភស្តុតាងពិតប្រាកដ បានផ្តល់មកជាហូរហែច្រើនឆ្នាំហើយ អំពីការប្រើប្រាស់ស្រុកខ្មែរ ជាប្រភពផ្តល់ស្បៀងសំរាប់ពួកយៀកកុង ។ ការវាយតម្លៃទៅលើ

ការដឹកជញ្ជូនស្បៀងទាំងអស់នេះ ស្ទើរតែពុំអាចធ្វើទៅបាន, ក៏ប៉ុន្តែគេដឹងយ៉ាងច្បាស់ណាស់ថា ចំនួនជាសរុបមានតិចតួចបំផុត បើគេប្រៀបផ្ទឹមទៅនឹងសេចក្តីត្រូវការនៃពួកទ័ពព្រៃ ហើយបើគេប្រៀបធៀបទៅនឹងអ្វីដែលពួកគេបានទទួលតាមរយៈស្រុកលាវ, តាមសមុទ្រ និងនៅក្នុងរង្វង់ស្រុកយួនខាងត្បូងតែម្តង ។ ភស្តុតាងក៏បានបង្ហាញឲ្យឃើញផងដែរថា ភាគច្រើននៃស្បៀងទទួលបានមកពីស្រុកខ្មែរ គឺសុទ្ធតែជារបស់របរដែលគេអាចទិញបាននៅតាមទីផ្សារ ជាពិសេសម្ហូបអាហារ, ថ្នាំពេទ្យ និងសំលៀកបំពាក់ ឬជារបស់របរដែលនាំចូលមកពីស្រុកខ្មែរ ការរយៈបណ្តាញជួញដូរធម្មតា និងសំខាន់បំផុតជាតិគីមីខ្លះៗសំរាប់ប្រើប្រាស់ក្នុងយុទ្ធសាស្ត្រ ។ ពួកឈ្លើយសង្គ្រាមយៀកកុង ក៏បានផ្តល់នូវចម្លើយពិស្តារផងដែរ អំពីការដឹកជញ្ជូនភស្តុភារនៅក្នុងស្រុកខ្មែរ រួមទាំងការទិញដូររបស់របរនៅតាមទីផ្សារសាធារណៈ ព្រមទាំងការប្រើប្រាស់ផ្លូវដឹកជញ្ជូន ពីស្រុកខ្មែរចូលមកស្រុកយួនខាងត្បូង ។

១៨- គេមានមូលហេតុខ្លះត្រូវជឿថា ពួកកុម្មុយនិស្តបានគិតគូររួចហើយ ថាការទទួលស្បៀងមកពីស្រុកខ្មែរមិនគ្រប់គ្រាន់ទេ ។ ក្នុងឱកាស«ប្រជុំការងារ»មួយនៅភ្នំពេញ, សីហនុបានចង្អុលបង្ហាញថាពួកយៀកកុងបានចូលមកជួបមេខាងសេដ្ឋកិច្ចខ្មែរគឺ សឺន-សាន ដើម្បីសុំទិញអង្ករពីខ្មែរ ។ ដោយគ្មានថ្លែងបញ្ជាក់ប្រាប់ឲ្យដឹងអំពីការសំរេចចិត្តដូចម្តេចទេ, តែសីហនុនិយាយថា ការរត់ពន្ធអង្ករចេញពីស្រុកខ្មែរទៅស្រុកយួន បានធ្វើឲ្យតម្លៃអង្ករឡើងថ្លៃយ៉ាងខ្ពស់ និងធ្វើឲ្យបាត់បង់ប្រាក់ចំណូលរដ្ឋាភិបាលយ៉ាងសំបើម ។ សីហនុទទួលស្គាល់ថា មានពួកមន្ត្រីស៊ីវិលនិងកងទ័ពខ្មែរ ប្រឡាក់ប្រឡូសនៅក្នុងអំពើជួញដូរនេះ ដោយសីហនុបានសុំឲ្យរកមធ្យោបាយសំរាប់«ទប់ស្កាត់អង្ករកុំឲ្យចេញពីស្រុក» ។ សេចក្តីរាយការណ៍បញ្ជាក់ថា ពួកយៀកកុងកំពុងធ្វើការចរចាទិញអង្ករប្រហែល៥,០០០តោន, ទោះបីកិច្ចព្រមព្រៀងគ្នានោះពុំទាន់បានសំរេចនៅឡើយយ៉ាងណាក្តី ។

១៩- ដល់ដូច្នេះទៅ គេមានសេចក្តីរាយការណ៍យ៉ាងច្រើនគួសបញ្ជាក់ថា ពួកយៀកកុងបានឆ្លៀតឱកាសយកប្រៀប លើអំពើរត់ពន្ធឆ្លងកាត់ព្រំដែនយួន-ខ្មែរនេះ ដោយការដឹកជញ្ជូនអាវុធយុទ្ធភ័ណ្ឌតាមរយៈស្រុកខ្មែរ ។ មានភស្តុតាងចេញពីការសួរចម្លើយខ្លះរាយការណ៍ថា ពួកទ័ពព្រៃមានទីកន្លែងផ្សេងៗសំរាប់លាក់អាវុធនៅក្នុងទឹកដីខ្មែរ រួចហើយក៏បានដឹកអាវុធនោះចុះឡើងនៅតាមបណ្តោយព្រំដែនផង ។ តែទោះបីយ៉ាងដូច្នេះក៏ដោយ គេមានភស្តុតាងតិចតួចណាស់ ដែលបញ្ជាក់ប្រាប់ថាខ្មែរគឺជាប្រភពឬជាបណ្តាញយ៉ាងសំខាន់ នៃការដឹកជញ្ជូនអាវុធទៅឲ្យពួកយៀកកុង

២០- សេចក្តីរាយការណ៍ជុំវិញលទ្ធភាពការដឹកជញ្ជូនអាវុធទៅឲ្យពួកយៀកកុងឆ្លងតាមស្រុកខ្មែរ គឺផ្តោតនៅត្រង់ម្តុំក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្ររបស់

ខ្មែរតែមួយគត់ ដែលអាចមានកប៉ាល់ចូលទៅដល់ផ្ទាល់ ។ ភាគច្រើននៃសេចក្តីរាយការណ៍ទាំងអស់នេះ ហាក់ដូចជាបង្ហាញឲ្យឃើញអំពីការដឹកប្រគល់មកឲ្យ ចាប់ផ្តើមពីចុងឆ្នាំ១៩៦៤ បន្តរហូតមកដល់ឆ្នាំនេះ នូវអាវុធយុទ្ធភ័ណ្ឌចេញពីចិនកុម្មុយនិស្តផ្តល់ដល់ខ្មែរ ។ គេពុំឃើញខាងខ្មែរនិងខាងចិនកុម្មុយនិស្ត លាក់បំពួនការដឹកជញ្ជូនអាវុធទាំងអស់នេះទេ ។ ការចូលទៅដល់កំពង់ផែនៃពួកអ្នកសង្កេតការណ៍បស្ចឹមប្រទេស ដូចជាបុគ្គលិកយោធាអូស្ត្រាលីនិងអង់គ្លេសជាដើម ក៏ពុំបានហាមឃាត់អ្វីដែរ ។ តាមពិតទៅ ដើម្បីជាការឃោសនា, សីហនុបានចង្អុលបង្ហាញអំពីការដឹកជញ្ជូន និងការរាយមុខនៃអាវុធទាំងអស់នេះផង ។ ហើយទោះបីយ៉ាងដូច្នេះក៏ដោយ គេក៏ពុំអាចតាមដាន ការចែកចាយកាំភ្លើងដៃនិងកាំភ្លើងយន្តរបស់ចិននោះបានឡើយ ។ គេនិយាយថា ឧបករណ៍ទាំងអស់នេះ ត្រូវបានយកទៅប្រើសំរាប់ទាហាននិងកងទ័ពប៉ារ៉ារបស់ខ្មែរ ។

២១- សីហនុមានការរសើបខ្លាំងណាស់ ចំពោះការចោទប្រកាន់ដែលនិយាយថា ពួកយៀកកុងកំពុងទទួលអាវុធតាមរយៈស្រុកខ្មែរ ។ មានម្តងនោះ, គាត់ផ្ទាល់ខ្លួនបានទៅដកហូតអាវុធពីអាណិកជនជាតិចិនម្នាក់នៅក្នុងកងអាសារស្ម័គ្រខ្មែរ ពីព្រោះមើលទៅប្រហែលមាន<ការយល់ច្រឡំ>ខ្លះៗ ។ សេចក្តីរាយការណ៍ពត៌មានថ្មីៗអំពីការប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុដោយពួកកុម្មុយនិស្ត បានធ្វើឲ្យសីហនុសុំ<គណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ> (ICC) ទៅពិនិត្យមើលដល់កំពង់ផែតែម្តង ។ គណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ (ICC) បានចុះទៅឆែកមើលកំណត់ហេតុការចុះបញ្ជីទំនិញនៅកំពង់ផែក្រុងព្រះសីហនុ ហើយនិងបានធ្វើការវាយតម្លៃតាមតម្រូវការផ្ទាល់ខ្លួន សំរាប់រក្សាទុកនូវក្រុមត្រួតពិនិត្យជាប្រចាំមួយ ។

២២- ទោះបីមានការត្រួតពិនិត្យមើលសព្វគ្រប់យ៉ាងណាក៏ដោយ គណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ (ICC) នៅតែពុំអាចធានាថា ពួកកុម្មុយនិស្តនឹងមិនប្រើប្រាស់ស្រុកខ្មែរ ដើម្បីដឹកជញ្ជូនឧបករណ៍យោធាទៅឲ្យពួកយៀកកុងបានឡើយ ។ (លទ្ធភាពផ្លូវផ្តល់ខ្មែរ សំរាប់គេប្រើប្រាស់ក្នុងការដឹកជញ្ជូននេះ ដោយលក្ខណៈសម្ងាត់និងបើកចំហ បានត្រូវពិនិត្យមើលនិងរាយការណ៍ក្នុងកំណត់ភ្ជាប់មកជាមួយនេះ) ។ ភស្តុតាងចំពោះហេតុការណ៍និងការពិតនោះគឺថា ពួកកុម្មុយនិស្តបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីធ្វើឲ្យកាន់តែប្រសើរនិងពង្រីកឲ្យកាន់តែធំឡើងៗ នូវបណ្តាញជ្រៀតចូលរបស់ពួកគេនៅខាងទឹកដីលាវ ។ តែទោះបីយ៉ាងណាក៏ដោយ ពួកគេក៏រំពឹងទៅលើផ្លូវផ្សេងៗដទៃទៀតផងដែរ យ៉ាងហោចណាស់នាអនាគតឆាប់ៗនេះ ។

២៣- មានកត្តាមួយចំនួនដែលត្រូវធ្វើការទប់ស្កាត់ ចំពោះការពង្រីកកាន់តែធំឡើង នៃការដឹកបញ្ជូនស្បៀងរបស់ពួកកុម្មុយនិស្តឆ្លងតាមស្រុកខ្មែរ ។ ពួកកុម្មុយ-

និស្តត្រូវតែមានការគាំទ្រពីសីហនុ ដើម្បីបើកទ្វារស្រុកខ្មែរនេះ ហើយក៏គ្មានអ្វីដែលត្រូវមន្ទិលសង្ស័យសោះឡើយ ដែលថាសីហនុត្រូវធ្វើការតបតដោយរួមសហប្រតិបត្តិយ៉ាងចេញមុខបែបនេះនោះ ។ ក្រោមកាលៈទេសៈបច្ចុប្បន្ន, វាជាការពិបាកខ្លាំងណាស់ក្នុងការប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ ឬក៏ផ្លូវដឹកស្បៀងផ្សេងៗសំខាន់ៗដទៃទៀត ដែលចៀសពីគេរកមើលមិនឃើញ ។ ពួកកុម្មុយនិស្តក៏មានការអល់អែកផងដែរ នៅក្នុងការរៀបចំបង្កើតផ្លូវដឹកស្បៀងដ៏សំខាន់មួយ ដែលពួកគេត្រូវរំពឹងទៅលើសីហនុ បុគ្គលម្នាក់ដែលកន្លងមក ពួកគេមិនសូវជាទុកចិត្តប៉ុន្មានឡើយ ។

## ជំរក

២៤- ភស្តុតាងបង្ហាញថា ពួកយៀកកុងបានប្រើប្រាស់ទឹកដីខ្មែរធ្វើជាជំរក ក្នុងរយៈពេលវាយប្រហារជាមួយកងទ័ពរដ្ឋាភិបាលយួនខាងត្បូង បានត្រូវគេរកឃើញចាប់តាំងពីថ្ងៃដំបូងនៃការកកើតចលនាបះបោរនេះម៉្លេះ ។ ទោះបីមានការបំផ្លើសខ្លះៗក៏ដោយ ជាភាគច្រើននោះបានរាយការណ៍ថា នៅពេលគេបាត់មិនឃើញពួកយៀកកុង គឺពួកនេះឆ្លងព្រំដែនចូលទៅក្នុងដីខ្មែរ ។ វាជាការច្បាស់ពិតប្រាកដណាស់ គឺពួកយៀងកកុងទាំងអស់នេះ នាំគ្នារត់ទៅរកទីកន្លែងសុខសប្បាយរបស់ខ្លួន ក្នុងទីកន្លែងជាច្រើនតាមបណ្តោយព្រំដែនខ្មែរ ។ សេចក្តីរាយការណ៍នានាបានបញ្ជាក់ថា ពួកទ័ពព្រៃបានសង់រូងនៅក្រោមដីជាច្រើនកន្លែង នៅជិតៗព្រំដែន ដើម្បីជាការងាយស្រួលពុំចាំបាច់ចូលជ្រៅទៅក្នុងទឹកដីខ្មែរ ។ ពេលពួកកុម្មុយនិស្តឆ្លងកាត់ ពួកនេះប្រយ័ត្នប្រយែងខ្លាំងណាស់ ដើម្បីចៀសវាងការជួបប្រទះគ្នាជាមួយពួកឆ្មាំប៉ុស្តិ៍ខ្មែរ ដែលគេបាននិយាយត្រូវរ៉ូវគ្នារួចស្រេចអស់ហើយអំពីរឿងនេះ ។

២៥- ទំហំនៃទីកន្លែងរបស់យៀកកុងនៅលើទឹកដីខ្មែរយ៉ាងដូចម្តេចនោះ គេមិនសូវច្បាស់ទេ គឺគេគ្រាន់តែដឹងថាស្ថិតនៅទីនេះឬទីនោះ តាមបណ្តោយព្រំដែនដែលមានប្រវែង៦០០ម៉ែល៍នោះប៉ុណ្ណោះ ។ ពត៌មានដ៏គួរឲ្យទុកចិត្តបានអំពីរឿងនេះ បានមកពីការសួរចម្លើយពួកអ្នកទោសយៀកកុង ។ សេចក្តីរាយការណ៍បញ្ជាក់ថា ទីកន្លែងទាំងអស់នោះច្រើនតូចៗ គេប្រើប្រាស់សំរាប់ឈប់សំរាក, ធ្វើជាឃ្លាំងផ្ទុករបស់របរ និងជាកន្លែងសំរាប់ហ្វឹកហ្វឺន ។ ជាភាគច្រើននោះ គេធ្វើចំនៅពីលើព្រំដែនតែម្តង ។

២៦- ការសួរចម្លើយថ្មីៗនេះចំពោះអ្នកទោសយួនខាងជើងម្នាក់ ជាការសួរចម្លើយដ៏សំខាន់ជាងគេទាំងអស់នៃសេចក្តីរាយការណ៍នេះ ពីព្រោះផ្តោតទៅលើតំបន់ផ្នែកចុងបំផុតនៅទិសខាងជើងឆៀងខាងកើតស្រុកខ្មែរ ដែលជាកន្លែងមានការត្រួតត្រាយ៉ាងខ្សត់ខ្សោយពីរដ្ឋាភិបាលភ្នំពេញ ហើយនិងជាកន្លែងដែលពួកកុម្មុយនិស្តប្រើប្រាស់ទឹកដីទីកន្លែងនោះ ដោយគ្មានការដឹងឮអ្វីទាំងអស់ពីពួកមន្ត្រីខ្មែរ ។ ប្រ-

ភពពត៌មាននេះបានត្រូវពួកអ្នកសារពត៌មានដកស្រង់ពាក្យសំដីថា ពួកគេបានទទួលជំនួយយ៉ាង<ចំហ>ចេញមកពីស្រុកខ្មែរ នៅពេលពួកគេចូលទៅដល់ទីនោះ ។

២៧- ជនរត់ចោលជួរបានរៀបរាប់អំពីកងឯកភាពរបស់ខ្លួន, គឺកងវរសេនាធំនៅសើងឡាំ ចេញមកពីទិសខាងត្បូងស្រុកលាវ ទៅកាន់ខេត្តប្លេគូ ឆ្លងកាត់តាមផ្លូវនៅក្នុងស្រុកខ្មែរជិតបណ្តោយព្រំដែនស្រុកយួនខាងត្បូង ។ ជននេះអះអាងថា គាត់បានឈប់សំរាកស៊ីបាយ៦កន្លែងនៅក្នុងទឹកដីខ្មែរ ទោះបីសេចក្តីរាយការណ៍បញ្ជាក់ថាទីកន្លែងទាំងអស់នោះស្ថិតនៅក្នុងទឹកដីយួនខាងត្បូងក៏ដោយ ។ គាត់បានអះអាងថា គាត់បានជួបប្រទះឃើញក្រុមអ្នកស្រុកតូចៗ ដឹកអង្ករទៅកាន់កន្លែងពីរ រួចហើយគាត់និយាយថា ពួកទាហាននៃកងឯកភាពរបស់គាត់ក៏បានទាក់ទងអ្នកស្រុកនៅត្រង់ទីកន្លែងនោះ ដើម្បីសុំម្ហូបអាហារនិងបារីផង ។

២៨- ភស្តុតាងរូបថតសកម្មភាពពួកយៀកកុងនៅក្នុងស្រុកខ្មែរ អាចយកមកប្រើប្រាស់បានតែបន្តិចបន្តួចប៉ុណ្ណោះ លើកលែងរូបថ្មីមួយបង្ហាញឲ្យឃើញសំណង់ប្រក់ស្បូវថ្មីមួយចំនួន ស្ថិតនៅចុងពោចទិសខាងជើងឆៀងខាងកើតស្រុកខ្មែរ ។ ផ្លូវលំកែកុនឡើងវិញ បានតភ្ជាប់ចេញពីទីកន្លែងនោះទៅកាន់សំណង់នៅក្នុងស្រុកលាវ ដែលបង្ហាញឲ្យជឿថា សកម្មភាពពុំមែនចេញមកពីខាងស្រុកខ្មែរទេ ។ ទីកន្លែងនោះពុំដែលមានការត្រួតត្រាពីខាងខ្មែរ និងមានជនជាតិតិចតួចប៉ុណ្ណោះរស់នៅ និងនៅក្នុងផែនទីរបស់ពួកកុម្មុយនិស្ត គេដាក់ថាជាផ្នែកមួយរបស់យួនទៅវិញ ។

២៩- រូបថតផ្សេងទៀតនៃតំបន់ព្រំដែនខ្មែរ ពិបាកធ្វើការថ្លឹងថ្លែងណាស់ ពីព្រោះគេពុំអាចបែងចែកគ្នារវាងពួកកុម្មុយនិស្ត និងសកម្មភាពត្រឹមត្រូវរបស់ប្រជាពលរដ្ឋខ្មែរ ។ រូបថតសិក្សាអំពីព្រំដែនខ្មែរមួយ និយាយពីខេត្តប្លេគូទល់មុខនឹងស្រុកខ្មែរជាឧទាហរណ៍ គ្រាន់តែបញ្ជាក់ថា ផ្លូវលំឆ្លងកាត់ព្រំដែននោះ មាននរណាម្នាក់បានសាងសង់ឡើង៦ឆ្នាំមកហើយ ចាប់ពីផ្លូវលេខ១៩ឆ្ពោះទៅព្រំដែនយួនខាងត្បូងដែលនៅត្រង់កន្លែងនោះជាតំបន់ប្រជុំដោយភូមិខ្មែរ ។ គេមានចម្លើយយ៉ាងសមរម្យអំពីរូបថតនេះ ។ គេនិយាយថាខាងភ្នំពេញមានកម្មវិធីលើកទឹកចិត្ត ឲ្យមានការតាំងទីលំនៅទីនោះ ពីព្រោះមកពីគេភ័យខ្លាចធ្លាក់ទៅក្រោមការកាន់កាប់របស់យួនហើយនិងគេចង់ពង្រីកការការពារឲ្យកាន់តែប្រសើរឡើង នៅតាមបណ្តោយព្រំដែនយួនទាំងមូល ជាពិសេសបានសាងសង់ផ្លូវថ្នល់ទៅកាន់ប៉ុស្តិ៍ដាច់ស្រយាលនានា ។

៣០- ជាសរុប, គេឃើញយ៉ាងច្បាស់ថា ពួកកុម្មុយនិស្តបានរៀបចំជាសម្ងាត់ និងប្រហែលបណ្តោះអាសន្ន នូវទីតាំងរបស់ខ្លួនក្នុងទឹកដីខ្មែរ ។ តែទីកន្លែងទាំងអស់នេះ គឺជាផ្នែកដ៏តូចមួយប៉ុណ្ណោះនៃការខំប្រឹងប្រែងរបស់ពួកកុម្មុយនិស្តនៅក្នុងស្រុកយួនខាងត្បូង បើគេប្រៀបធៀបទៅនឹងទីកន្លែងធំៗនៅក្នុងទឹកដីយួនផ្ទាល់ ។

## នយោបាយ

៣១- ការប្រើប្រាស់នយោបាយស្រុកខ្មែរ ចំពោះពួកកុម្មុយនិស្ត គឺគ្មានអ្វីជាក់ស្តែងជាងការប្រើប្រាស់ស្រុកនេះ សំរាប់ជាប្រភពផ្តល់ស្បៀងនិងសំរាប់ធ្វើជាទីជំរកនោះទេ ឬមួយប្រហែលមានសារសំខាន់ច្រើនជាងនេះ ។ រហូតណា<អព្យាក្រឹត្យភាព>របស់សីហនុលំអៀងទៅខាងកុម្មុយនិស្ត និងរហូតណាគាត់នៅប្រកាន់យកតាមបន្ទាត់នយោបាយរបស់ពួកកុម្មុយនិស្ត លើបញ្ហាអន្តរជាតិជាបន្តបន្ទាប់គ្នាជាច្រើន ដើម្បីជាផលប្រយោជន៍របស់ខ្មែរ, នោះប៉េកាំងនិងហាណូយបានទទួលនូវការចំណោញឃោសនាយ៉ាងសំបើមពីភ្នំពេញ ។ ស្ថានភាពនេះគឺពុំមែនគ្មានការចំអកឡកលើយនោះទេ, ចំពោះសីហនុគឺដើម្បីជួយដល់ពួកកុម្មុយនិស្ត ដោយលេសថាគាត់ពុំមែនជាជនកុម្មុយនិស្ត ហើយនិងគាត់អាចបន្តបង្ហាញមុខមាត់របស់គាត់ ជាមេដឹកនាំជាតិដ៏ត្រឹមត្រូវ សូម្បីអន្តរជាតិក៏គេយល់ថា គាត់មានការប្រឡាក់ប្រឡូសគ្រាន់បើដែរ ទោះបីគាត់ប្រកាន់នូវអព្យាក្រឹត្យភាពនិយមយ៉ាងណាក៏ដោយ ។ គឺមកពីមូលហាតុនេះឯងហើយ ទើបចិនមានការពេញចិត្តយ៉ាងខ្លាំងនិយាយប្រាប់សីហនុថា ចិនចង់បានស្រុកខ្មែរស្ថិតនៅជាស្រុក«អព្យាក្រឹត្យ» ។

៣២- ពួកយៀកកុងក៏បានអូសទាញយកចំណោញនយោបាយផងដែរ ពី<អព្យាក្រឹត្យភាព>របស់ខ្មែរ ដែលប្រហែលមានសារសំខាន់ធំជាងការទទួលស្គាល់នូវអព្យាក្រឹត្យភាពនេះទៅទៀត ។ ការនេះ មិនត្រឹមតែពួកយៀកកុងបានទទួលនូវសេចក្តីសុខ ពីការអះអាងរបស់សីហនុ ថាពួកគេជា «អ្នកបំរើ»ឲ្យជនជាតិយួននៅសៃហ្កុងតែប៉ុណ្ណោះទេ គឺថ្នាក់ដឹកនាំយៀកកុងមានជំនឿយ៉ាងមាំ ក្នុងការប្រើប្រាស់អព្យាក្រឹត្យភាពខ្មែរ ដើម្បីទំនាក់ទំនងគ្នាយ៉ាងសុខសាន្តយូរអង្វែង ជាមួយស្រុកយួនខាងជើងនិងស្រុកចិន ឆ្លងតាមរយៈស្រុកខ្មែរ ។ មានអ្នកខ្លះនិយាយថា ស្រុកខ្មែរគឺជាទីកន្លែងសំរាប់ពួកយៀកកុងធ្វើសកម្មភាពនយោបាយរាប់សិបឆ្នាំមកហើយ ជាច្រកទ្វារបើកទៅរកពិភពលោកខាងក្រៅ ឆ្លងតាមរយៈពួកអ្នកកាសែតជាមិត្តរបស់ខ្លួន ដែលអាចធ្វើដំណើរទៅដល់ជំរកកងទ័ពព្រៃ ដែលស្ថិតនៅស្រុកយួនខាងត្បូង ។

## ការឃុបឃិតស៊ីគ្រលុំ

៣៣- គេមានពត៌មានយ៉ាងគ្រប់គ្រាន់ នៅលើបញ្ហាដែលថាខ្មែរមានការចូលរួមដៃជាផ្លូវការជាមួយពួកយៀកកុង ក្នុងការប្រើប្រាស់ទឹកដីខ្មែរ ។ ពីរបាយការណ៍សួរចម្លើយ និងពីប្រភពផ្សេងៗទៀតបាននិយាយថា មានទីកន្លែងជាច្រើននៅតាមបណ្តោយព្រំដែន ពួកយៀកកុងបានស្រុះស្រួលត្រូវរ៉ូវគ្នាជាមួយកងកម្លាំងខាងខ្មែរ ដោយគេអនុញ្ញាតឲ្យពួកកងទ័ពព្រៃ រត់មកជ្រកកោនដើម្បីគេចចៀសពីកម្លាំងទ័ពយួ

នខាងត្បូង ។ ពួកអ្នកទោសក៏បានរាយការណ៍ផងដែរថា នៅតាមទីកន្លែងខ្លះ ពួកអាជ្ញាធរខ្មែរគ្មានទាំងរវល់ចាប់អារម្មណ៍អ្វីទាំងអស់ ក្នុងការដឹកជញ្ជូនស្បៀងដល់ពួកយៀកកុងពីស្រុកខ្មែរថែមទៀតផង ។ បើពួកកុម្មុយនិស្តមានបញ្ហាបន្តិចបន្តួចជាមួយជនជាតិខ្មែរនៅតាមកន្លែងខ្លះ គេពុំឃើញមានបញ្ហាដូចគ្នាកើតនៅកន្លែងផ្សេងឡើយ ។ គេសង្កេតឃើញមានឧប្បត្តិហេតុពើបប្រយុទ្ធអាវុធគ្នាចំនួនប្រហែលប្រាំបីដង រវាងកងកម្លាំងខ្មែរការពារព្រំដែន និងពួកយៀកកុង បានកើតឡើងនៅក្នុងឆ្នាំនេះ។ មានពេលខ្លះ កងទ័ពខ្មែរក៏បានបើកប្រតិបត្តិការបោសសំអាត ប្រឆាំងពួកយៀកកុង ដែលគេមន្ទិលសង្ស័យរំលោភលើទឹកដីផងដែរ ។ រូបភាពចំរូងចំរះគ្នារវាងយួន-ខ្មែរទាក់ទិននឹងបញ្ហាព្រំដែននេះ គឺចង់ប្រាប់ថា គ្មាននយោបាយខាងភ្នំពេញគាំទ្រដោយចំពោះ ទៅលើពួកកងទ័ពព្រៃកុម្មុយនិស្តទេ ។ នាប៉ុន្មានខែថ្មីៗនេះ, បន្ថែមពីលើនេះ, ភាពរសើបនៃរដ្ឋាភិបាលក្រុងភ្នំពេញ ចំពោះកិច្ចប្រតិបត្តិការសម្ងាត់របស់ពួកយៀកកុង គឺគេបានឃើញពួកមេបញ្ជាការនៅតាមព្រំដែន បានចាត់វិធានការដើម្បីធានាមិនឲ្យមានអំពើរត់ពន្ធអង្ករនិងអាវុធខុសច្បាប់ ឆ្លងចូលទៅស្រុកយួនខាងត្បូងថែមទៀតផង ។

៣៤- ភស្តុតាងដ៏សំខាន់ជាងគេ ដែលចង្អុលឲ្យឃើញថា ភ្នំពេញគ្មានសម្ព័ន្ធភាពជាមួយពួកយៀកកុង ឬសូម្បីតែគេជឿថាទឹកដីខ្មែរជាទីកន្លែងជំរកដ៏សំខាន់នៃពួកទ័ពព្រៃនោះ គឺប្រហែលមកពីការស្ម័គ្រចិត្តបើកចំហទឹកដីខ្មែរ ឲ្យប្រទេសខាងក្រៅចូលទៅពិនិត្យមើលទេដឹង ។ ស្រុកខ្មែរបើតាមឯកសារ បានគាំទ្រគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ (ICC) ចូលទៅធ្វើការពិនិត្យមើលនិងត្រួតត្រាទឹកដីរបស់ខ្លួន ។ តែទោះបីជាមានសុទ្ធចិត្តយ៉ាងដូច្នេះក៏ដោយ ការផ្តល់នេះពុំបានសាកល្បងមើលឡើយ ។ សីហនុ បានបើកទីកន្លែងរសើបៗ ឲ្យពួកមន្ត្រីបស្ចឹមប្រទេសធ្វើការពិនិត្យមើល និងបានហៅពួកអ្នកកាសែតអាមេរិកាំង ឲ្យទៅធ្វើការពិនិត្យមើលស្រុខ្មែរដោយផ្ទាល់ផងដែរ ។ តែទោះបីមានការត្រួតពិនិត្យ«យ៉ាងឆាប់រហ័ស»បែបនេះមែនពិត តែគេក៏រឹតព្រំដែននិងសេរីភាព មិនឲ្យដើរចេញទៅក្រៅពីអ្វីដែលបានកំណត់ទេ នេះបើយោងតាមសំដីសារភាពរបស់ពួកអ្នកកាសែតអាមេរិកាំងទាំងនោះ ។ ទីកន្លែងដែលពួកគេបានដល់ គ្មានឃើញអ្វីគួរជាទីលាក់កំបាំងសោះ ។

៣៥- ការដែលភ្នំពេញ និងជាពិសេសសីហនុ ដែលគេដឹងមានការពាក់ព័ន្ធជាមួយពួកយៀកកុង កើតឡើងនៅក្នុងទីកន្លែងខ្លះតាមបណ្តោយព្រំដែននោះ ក៏មិនជាច្បាស់ពិតប្រាកដទាំងអស់ដែរ ។ សីហនុបានបដិសេធទាំងទទូចរាប់សិបឆ្នាំមកហើយថា ពួកយៀកកុងពុំដែលបានប្រើប្រាស់ទឹកដីខ្មែរទេ ។ ក៏ប៉ុន្តែនៅក្នុងពេលជាមួយគ្នានោះ, សីហនុបានដឹងយ៉ាងច្បាស់ណាស់ នូវអំពើពុករលួយប្លែកៗនៃពួកម-

ន្ត្រីខ្មែរ ពីថ្នាក់លើចុះដល់ថ្នាក់ខាងក្រោម ។ ជាការពិត, សីហនុដឹងថា ពួកយៀកកុងអាចធ្វើអ្វីបានច្រើនយ៉ាងនៅក្នុងស្រុកខ្មែរ ដោយយកប្រៀបលើអំពើលោភលន់ហួសប្រមាណនេះ ។ បើសីហនុមិនបានដឹងស្ថានភាពទាំងមូលនៅតាមបណ្តោយព្រំដែនទេ លន់-នល់ពិតជាដឹង ។ លន់-នល់បានត្រូវគេរាយការណ៍យ៉ាងច្បាស់ថា គាត់មានការព្រួយបារម្ភចំពោះពួកកុម្មុយនិស្ត «ដែលចែកគ្នាជាក្រុមតូចៗ» យកប្រៀបទឹកដីខ្មែរ ក្នុងរយៈពេលវាយប្រយុទ្ធនៅជិត ប្លៃមី ។ គាត់បានបញ្ជាក់ថា នៅក្នុងរឿងនេះ កម្លាំងការពារព្រំដែនខ្មែរដែលគ្មានមនុស្សគ្រប់គ្រាន់ ពុំអាចធ្វើអ្វីបានសោះឡើយ ។

៣៦- ពីគំនិតរបស់សីហនុ, ការផ្តល់ស្បៀងទៅឲ្យពួកកងទ័ពព្រៃកុម្មុយនិស្ត គឺពាក់ព័ន្ធដល់ការប្រថុយប្រថានធ្ងន់ធ្ងរណាស់ ដោយគ្មានបានទទួលអ្វីមកវិញក្នុងភាពស្មើគ្នានោះទេ ។ សីហនុសុខចិត្តគាំទ្រពួកកុម្មុយនិស្ត ដោយធ្វើការផ្តល់អំណោយសាធារណៈជាថ្នាំពេទ្យ តែនៅក្នុងពេលជាមួយគ្នា ច្រានចោលសំណូមពរជំនួញបន្ថែម ជាពិសេសសម្ភារយោធាជាដើម ដែលជារឿងមួយបែបផ្សេងទៀត ។

❑

## ឯកសារភ្ជាប់

# កុម្មុយនិស្តប្រើប្រាស់ស្រុកខ្មែរ ក្នុងការគាំទ្រសង្គ្រាមនៅវៀតណាមខាងត្បូង

១- បើរដ្ឋាភិបាលខ្មែរបើកចំហអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីរបស់ខ្លួន ដើម្បីគាំទ្រសកម្មភាពយោធាពួកកុម្មុយនិស្តនៅវៀតណាមខាងត្បូង, ពួកយៀកកុងមុខជាបញ្ចេញឲ្យឃើញ នូវការចេញចូលប្រើប្រាស់បាននៃព្រំដែនខ្មែរ-យួន ប្រវែងប្រហែល ៦០០ម៉ែល៍ ដែលពួកគេអាចប្រើប្រាស់ធ្វើជាទីកន្លែងជំរក និងឃ្លាំងផ្ទុកសម្ភារៈ, ជំរំសំរាប់សំរាក, ទីកន្លែងសំរាប់ហ្វឹកហាត់, មន្ទីរពេទ្យ និងកន្លែងរោងជាង ជាដើម ។ លើសពីនេះ ពួកគេអាចពង្រីកប្រព័ន្ធផ្តល់ស្បៀងយ៉ាងសំខាន់និងប្រកបដោយសន្តិសុខ ឆ្លងចូលទៅក្នុងតំបន់ដីសណ្តនៃប្រទេសវៀតណាមខាងត្បូង ។ ប្រព័ន្ធផ្តល់ស្បៀងនេះអាចមានលទ្ធភាពផ្តល់បន្ថែម រហូតដល់ទៅ១,២០០តោននូវស្បៀងដល់កងទ័ព ដែលយើងធ្វើការប៉ាន់ស្មាន អាចទទួលប្រចាំថ្ងៃចេញពីកំពង់ផែក្រុងព្រះសី

ហានុ ។ លទ្ធភាពនេះ គឺមានចំនួនជាង៧ដងលើសកំរិតអតិបរមានៃតំរោងការ គឺត្រូវជា១៦៥តោន នៃស្បៀងដែលគេតម្រូវទទួលមកពីខាងក្រៅ សំរាប់ពង្រឹកកម្លាំងកងទ័ពយៀកកុង-យៀកណាមខាងជើង អាចធ្វើការវាយប្រហារយ៉ាងខ្លាំងក្លានៅវៀត-ណាមខាងត្បូង ។ លទ្ធភាពកងទ័ពយៀកកុង-យៀកណាមខាងជើងអាចបង្កសង្គ្រាមនៅតំបន់ខ្ពង់រាបវៀតណាមខាងត្បូងបាន គឺពុំអាចកើតឡើងពីការប្រើប្រាស់ទឹកដីខ្មែរនេះឡើយ ។ តំបន់ខ្ពង់រាបភាគកណ្តាល គឺមានការងាយស្រួលនឹងទទួលស្បៀងផ្ទាល់ពីខាងស្រុកលាវឯណោះទៅវិញទេ ។

២- ទោះបីគ្មានសហប្រតិបត្តិការពីរដ្ឋាភិបាលខ្មែរក៏ដោយ, ពួកកុម្មុយនិស្តក៏អាចប្រើប្រាស់ទឹកដីខ្មែរបានដែរ ។ ពួកគេអាចពង្រឹកការជ្រៀតចូលដែលមានទំហំតូចៗ ដោយបញ្ជូនមនុស្សថែមទៀត ឲ្យទៅទិញស្បៀងនៅតាមទីផ្សារ ហើយនិងបង្កើនការនាំចូលស្របច្បាប់តាមរយៈហាងទំនិញនានា ដែលជាបណ្តាញរបស់គេនៅក្នុងទីក្រុងភ្នំពេញ ។ ស្បៀងដែលបានមកតាមវិធីនេះ គឺត្រូវវត់ពន្ធឆ្លងព្រំដែន ឬមួយតាមវិធីសម្ងាត់ផ្សេងៗ ។ ពួកគេក៏មានតំបន់ព្រំដែនដាច់ស្រយាលជាច្រើនទៀតដែរ ដែលរដ្ឋាភិបាលខ្មែរគ្មានការត្រួតត្រាជិតដល់ ។ តំបន់ទាំងនោះ តាមពិតគឺសំរាប់ប្រើប្រាស់ខាងផ្នែកកងទ័ព ។

៣- ចាប់តាំងពីលទ្ធភាពនៃប្រព័ន្ធដឹកជញ្ជូនស្បៀងឆ្លងតាមស្រុកលាវ ល្អប្រ-សើរតាមតំរូវការរបស់ពួកយៀកកុង-យៀកណាមខាងជើង, ការប្រើប្រាស់ទឹកដីខ្មែរ គឺជាច្រកផ្លូវបន្ទាប់បន្សំប៉ុណ្ណោះ ។ យើងបានធ្វើការប៉ាន់ស្មានថា បើគេបូកបញ្ចូលគ្នា ទាំងការប្រើប្រាស់តាមបណ្តាញការទិញដូរធម្មតា និងទាំងការប្រើប្រាស់វិធីសម្ងាត់ ពួកកុម្មុយនិស្តអាចទទួលបានស្បៀងមិនជាច្រើនប៉ុន្មានទេ ឆ្លងតាមរយៈស្រុកខ្មែរ ។ ពួកគេចាំបាច់ត្រូវតែពឹងតាមច្រកស្រុកលាវ ។ ទោះបីក្នុងអនុស្សារណៈនៃក្រសួងស៊ើបការសម្ងាត់អាមេរិកាំងថ្មីៗនេះ ស្តីអំពី «ការជ្រៀតចូល និងការផ្តល់ភស្តុភារនៅវៀតណាមខាងត្បូង» ចុះថ្ងៃទី២៨តុលា១៩៦៥, ជាការសម្ងាត់ពុំអាចចែកផ្សាយដល់បរទេសក៏ដោយ ក៏ពុំអាចបញ្ជាក់ឲ្យច្បាស់អំពីទំហំនៃស្បៀង ដែលបានឆ្លងកាត់ស្រុកខ្មែរនោះឡើយ ដោយគ្រាន់តែនិយាយថាមានចំនួនតូច មិនលើសពីមួយតោនទៅពីរតោនជារៀងរាល់ថ្ងៃប៉ុណ្ណោះ ។ តាមពិតទៅ ពួកកុម្មុយនិស្តពិតជាអាចបង្កើនទំហំលើសអំពីនេះស្មានមិនដល់ ។ គ្រាន់តែតាមវិធីសម្ងាត់តែមុខគត់ គេអាចដឹកជញ្ជូនស្បៀងកងទ័ពជាមធ្យមចំនួន១២តោន សំរាប់តម្រូវការប្រចាំថ្ងៃនៃពួកកងទ័ពយៀកកុង-យៀកណាមខាងជើងនៅស្រុកយួនខាងត្បូង ។ រឿងនេះវាត្រូវតែគ្មានមន្ទិលសង្ស័យសោះឡើយ ថាកំពង់ផែក្រុងព្រះសីហនុអាចបញ្ជូនទូវទំហំប៉ុ-ណ្ណោះ ដោយគ្មាននរណារកដឹង ។ បើស្បៀងចំនួន១២តោន អាចទម្លាក់ចុះនៅក្រុង

ព្រះសីហនុ និងនៅតាមចំណុចណាផ្សេងតាមច្រាំងសមុទ្របាន, ពួកកុម្មុយនិស្តពិតជាអាចដឹកជញ្ជូនស្បៀងនោះចូលមកស្រុកយួនខាងត្បូង ដោយគ្មានមន្ទិលសង្ស័យសោះឡើយ ។ យ៉ាងតិចបំផុត, ពួកកុម្មុយនិស្តក៏អាចដឹកជញ្ជូនស្បៀងយ៉ាងសម្ងាត់ឆ្លងកាត់ស្រុកខ្មែរ គ្រប់គ្រាន់ល្មមសំរាប់បង្គ្រប់ទៅលើចំនួនស្បៀង ដែលពួកគេដឹកចូលមកតាមសមុទ្រដែរ ។

៤- បើស្រុកខ្មែរផ្តល់នូវសហប្រតិបត្តិយ៉ាងចំហ ដោយការផ្តល់នូវស្បៀងដ៏មានទំហំយ៉ាងធំដល់ពួកយៀកកុង គឺមានតែចូលតាមកំពង់ផែក្រុងព្រះសីហនុ ។ រយៈកាលឆ្នាំ១៩៦៤, កំពង់ផែនេះអាចទទួលទំនិញចំនួន៨០០,០០០តោន ដែលនៅក្នុងនោះ២២០,០០០តោន ជាទំនិញនាំចូល ។ ក្រោមប្រតិបត្តិការធម្មតា, កំពង់ផែអាចទទួលទំនិញនាំចូលបន្ថែម យ៉ាងហោចណាស់ក៏៤៥០,០០០តោនថែមទៀតក្នុង១ឆ្នាំៗ ឬជាមធ្យមចំនួនប្រហែល១,២០០តោនក្នុង១ថ្ងៃ ។ ក្រៅពីកំពង់ផែក្រុងព្រះសីហនុដ៏សំខាន់នេះ, ខ្មែរមានកំពង់ផែតូចៗបីទៀត ដែលភាគច្រើនប្រើប្រាស់សំរាប់ការនេសាទ និងសកម្មភាពទ័ពជើងទឹក ។ ការទម្លាក់ទំនិញតាមកំពង់ផែទាំងនេះ បានតែតិចតួចតោនប៉ុណ្ណោះ ក៏ប៉ុន្តែគេអាចដឹកជញ្ជូនតាមកប៉ាល់តូចៗក៏បានដែរ ។ ផ្នែកដែលសំខាន់ជាងគេនោះ គឺការដឹកនៅតាមផ្លូវគោក ។ នៅស្រុកខ្មែរ បើតាមការប៉ាន់ស្មាន មានឡានកាម្យ៉ុងចំនួនប្រហែល១០,០០០គ្រឿង ដែលអាចធ្វើការដឹកជញ្ជូនបានយ៉ាងងាយ ។ ផ្លូវរថភ្លើងពីក្រុងព្រះសីហនុទៅកាន់ទីក្រុងភ្នំពេញ កំពុងស្ថាបនាប្រហែលប្រាំឆ្នាំមកហើយ តែស្ពានមួយចំនួនធំ ហើយនិងការដាក់ផ្លូវដែកចំនួនប្រវែង១៦០ម៉ែល៍នោះ មិនទាន់បានចប់សព្វគ្រប់នៅឡើយទេ ។

៥- ផ្លូវថ្នល់ចេញពីក្រុងព្រះសីហនុ អាចមានលទ្ធភាពជាងកំពង់ផែនោះទៅទៀត ហើយអាចដឹកជញ្ជូនស្បៀងយោធារហូតដល់ទៅ១,២០០តោនបានយ៉ាងងាយស្រួលទៅកាន់ស្រុកយួនខាងត្បូង ។ ផ្លូវសំខាន់ដែលគេប្រើប្រាស់ គឺផ្លូវជាតិលេខ៤ មានប្រវែង១៨៥ម៉ែល៍ ពីក្រុងព្រះសីហនុទៅកាន់ទីក្រុងភ្នំពេញ ជាផ្លូវមិត្តភាពខ្មែរ-អាមេរិកាំង ។ ផ្លូវនេះអាចដឹកបាន៨,១៥០តោនក្នុងមួយថ្ងៃនៅរដូវប្រាំង និងដឹកបាន៧,៣៥០តោននៅខែវស្សា ។ ចេញពីទីក្រុងភ្នំពេញទៅកាន់ព្រំដែន គឺផ្លូវជាតិលេខ១ ដែលលាតសន្ធឹងទៅទិសខាងកើត ឆ្ពោះទៅកាន់ព្រំដែនទិសខាងត្បូងឆៀងខាងកើតនៃខេត្តតៃនិញ ។ ផ្លូវនេះអាចដឹកបាន៩,២០០តោនក្នុងមួយថ្ងៃនៅខែប្រាំង និងដឹកបាន១,៨០០តោនក្នុងមួយថ្ងៃនៅរដូវវស្សា ។ ចលនាទំនិញ១,២០០តោនរៀងរាល់ថ្ងៃពីក្រុងព្រះសីហនុទៅកាន់ព្រំដែនតាមផ្លូវនេះ តម្រូវប្រើប្រាស់ឡានកាម្យ៉ុងចំនួនពី១,៥០០ទៅ២,០០០គ្រឿង (ដោយសន្មត់ថាឡានកាម្យ៉ុងនិមួយៗអាចដឹកបាន៣.៥តោន) ។ គេក៏មានផ្លូវពីរទៀតផងដែរ ចេញពីទិសខាងជើងចូលទៅក្រុងភ្នំពេញ រួចត

ភ្ជាប់ជាមួយផ្លូវជាតិលេខ៧ ដែលអាចទៅព្រំដែនទិសខាងជើងខេត្តតែនិញ ។ ផ្លូវនេះ មានលទ្ធភាពទាបជាងផ្លូវជាតិលេខ១ ជាពិសេសនៅរដូវវស្សា ហើយចម្ងាយទៅព្រំដែនក៏ឆ្ងាយទៀត ។ ពីក្រុងភ្នំពេញ មានផ្លូវពីរខ្លីបន្តិច ដែលអាចទៅដល់ព្រំដែនខេត្តគៀងយ៉ាងនិងខេត្តចូវដុក ។ យ៉ាងហោចណាស់ ក៏គេឃើញមានទំនិញចំនួន១,២០០តោនជារៀងរាល់ថ្ងៃ បានដឹកឆ្លងកាត់តាមផ្លូវទាំងពីរនេះរាប់ឆ្នាំមកហើយ ។៚

~ ចប់ ~